**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
**រវាង**

## ក្រុមហ៊ុន ដឹ សូលហ្គៀ ខេមបូឌា ឯ.ក
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក សហជីព និងប្រធានក្រុម ប្រធានផ្នែក ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ១៣ និង៣០នាទី រសៀល នៅក្នុងរោងចក្រ ដឹ សូលហ្គៀ ខេមបូឌា ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន នឹងតំណាងកម្មករ និយោជិត សហជីព និង ប្រធានក្រុម ប្រធានផ្នែក នៅក្នុងអង្គប្រជុំនេះ តំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្ដីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះអ្នកបញ្ជាទិញដែលបណ្ដាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតចំនួន ៣០៤ នាក់(ស្រី ២៣០នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣២៨នាក់(ស្រី ២៤៥នាក់)រយៈ ពេល ១៤ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២៣ ។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិតម្នាក់ៗបានឯកភាពទទួលការផ្ដល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ១៥ដុល្លារសហរដ្ឋអាមេរិក គិតពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ដែលត្រូវបើកជូននៅ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង១៤ និង ២០នាទី រសៀល នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីក រាយ និងស្និតស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
កណ្ដាល ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣
**តំណាងនាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ដឹ សូល ហ្គៀ (ខេមបូឌា) ឯ.ក THE SOUL GEAR (CAMBODIA) CO.,LTD. KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករ និយោជិត**
**កិច្ចពមព្រៀង**
**រវាង**
**ក្រុមហ៊ុន ដឹ សូលហ្គៀ ខេមបូឌា ឯ.ក**
**ជាមួយតំណាងកម្មករ ប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រធានផ្នែក ប្រចាំក្រុមហ៊ុន**

១. នុត ណុល ២.នៅ ណារី ៣. សមប៊ុន មេសា ៤. សាត់ ចន្ថា

៥. ធី ស្រីណាន